ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
MINISTRY OF ECONOMY AND FINANCE

# ខ្លឹមសារដកស្រង់ នៃ
# ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម
# ឆ្នាំ ២០២៧-២០២៩



# ក. សេចក្ដីផ្ដើម

## តើក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម មានន័យដូចម្ដេច ?




### ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម

- ឯកសារគន្លឹះរបស់រាជរដ្ឋាភិបាល ដែលផ្ដល់ទស្សនវិស័យ និងការប៉ាន់ស្មានពីធនធាន និងបន្ទុកថវិការបស់រដ្ឋ
- កំណត់ដំបូរគោលនយោបាយថវិកា កំណត់ពិតានចំណាយថវិកាថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- កំណត់ពិតានតម្រូវការហិរញ្ញប្បទាន និងវាយតម្លៃហានិភ័យហិរញ្ញវត្ថុសាធារណៈ សម្រាប់រយៈពេលមធ្យមដោយផ្អែកលើមូលដ្ឋាន នៃទស្សនវិស័យម៉ាក្រូសេដ្ឋកិច្ច និងអាទិភាពគោលនយោបាយរបស់រាជរដ្ឋាភិបាល ដើម្បីធានាបាននូវចីរភាពហិរញ្ញវត្ថុសាធារណៈ ។

(ប្រភព៖ សន្ធានុក្រម នៃច្បាប់ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ឆ្នាំ២០២៣)

ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម ឆ្នាំ ២០២៧-២០២៩ ត្រូវបានដាក់ចេញ ដោយផ្ដល់នូវទស្សនវិស័យ និងការតម្រង់ទិសការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ ក្នុងរយៈពេលមធ្យម ព្រមទាំងសម្រួចទិសដៅអាទិភាពគោលនយោបាយរបស់រាជរដ្ឋាភិបាល និងគោលការណ៍ប្រើប្រាស់ធនធានជាតិ ប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព ។

ឯកសារនេះ ក៏ដើរតួនាទីស្នូល ក្នុងការពង្រឹងការផ្សារភ្ជាប់រវាងគោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងការរៀបចំថវិកាប្រចាំឆ្នាំ ដើម្បីវិភាជធនធាន ឱ្យស្របតាមអាទិភាពគោលនយោបាយអភិវឌ្ឍន៍ជាតិ និងពង្រឹងសមត្ថភាពក្នុងការឆ្លើយតបបានទៅនឹងបញ្ហាប្រឈម ដែលកំពុងកើតមានឡើងជាបន្តបន្ទាប់ ។



**ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈ ២០២៧-២០២៩**

ត្រូវបានរៀបចំក្នុងទម្រង់ ៣ ឆ្នាំរំកិល ក្នុងគោលបំណងសំខាន់ៗចំនួន ៤ រួមមាន ៖

១. ធានាឱ្យបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងចីរភាពហិរញ្ញវត្ថុសាធារណៈ

២. គាំទ្រការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាល

៣. ពង្រឹងប្រសិទ្ធភាពនៃការប្រមូលចំណូល និងការវិភាជថវិកា

៤. បង្កើនតម្លាភាពនៃគោលនយោបាយហិរញ្ញវត្ថុសាធារណៈ

# ២. យុទ្ធសាស្ត្រហិរញ្ញវត្ថុសាធារណៈ

«ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម ឆ្នាំ ២០២៧-២០២៩» ឬហៅខ្លីថា «ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈ ២០២៧-២០២៩» នេះ ដាក់ចេញនូវយុទ្ធសាស្ត្រហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល សម្រាប់រយៈពេលមធ្យម ដោយកំណត់នូវ **ជំហរគោលនយោបាយហិរញ្ញវត្ថុសាធារណៈ**, **វិធានហិរញ្ញវត្ថុសាធារណៈ**, និង **អាទិភាពគោលនយោបាយ** ។

## ២.១. ជំហរគោលនយោបាយហិរញ្ញវត្ថុសាធារណៈ

**ជំហរគោលនយោបាយហិរញ្ញវត្ថុសាធារណៈ** មានគោលបំណងធានាឱ្យបាននូវចីរភាពហិរញ្ញវត្ថុសាធារណៈក្នុងរយៈពេលមធ្យម ដោយបន្តរក្សាស្ថិរភាពសេដ្ឋកិច្ច និងតុល្យភាពថវិកា ដោយពុំប្រើប្រាស់ប្រាក់សន្សំរបស់រាជរដ្ឋាភិបាល ។ **ជំហរគោលនយោបាយហិរញ្ញវត្ថុសាធារណៈ** សម្រាប់រយៈពេលមធ្យមខាងមុខ នឹងត្រូវរៀបចំឡើងវិញដោយប្រកាន់យកនូវជំហរថ្មីគឺ «**ជំហរអព្យាក្រឹត**» ។ ការកំណត់យក **ជំហរអព្យាក្រឹត** នេះមានភាពសមស្របទៅនឹងស្ថានភាពមិនប្រាកដប្រជាខ្ពស់ ខណៈប្រភពហិរញ្ញប្បទានត្រូវបានរំពឹងទុកថានឹងថមថយ ដែលតម្រូវឱ្យចំណាយសាធារណៈ កើនស្របតាមលទ្ធភាពធនធានថវិកា ដើម្បីរក្សាភាពឆ្លើយតបបានទៅនឹងបរិការណ៍ដែលមិនទាន់អាចប្រមើលឃើញ ដោយចៀសវាងនូវការគ្រោងចំណាយខ្ពស់ជាងតម្រូវការជាក់ស្តែង និងការបង្កើនហិរញ្ញប្បទានបន្ថែមដោយគំហុក ។





## ២.២. វិធានហិរញ្ញវត្ថុសាធារណៈ

**វិធានហិរញ្ញវត្ថុសាធារណៈ** គឺជាផ្នែកមួយដ៏សំខាន់ ក្នុងការពង្រឹងប្រសិទ្ធភាពនៃការរៀបចំក្របខ័ណ្ឌថវិកា, ពង្រឹងតម្លាភាព និងគណនេយ្យភា,លើកកម្ពស់វិន័យ និងស្មារតីប្រុងប្រយ័ត្នក្នុងការអនុវត្តថវិកា និង ជាពិសេស ធានានូវចីរភាពហិរញ្ញវត្ថុសាធារណៈសម្រាប់រយៈពេលមធ្យម ។ ស្របតាមឧត្តមានុវត្តន៍ជាអន្តរជាតិ, វិធានហិរញ្ញវត្ថុសាធារណៈ ដែលត្រូវបានដាក់ចេញក្នុង ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈ ២០២៧-២០២៩ នេះ ត្រូវបានបែងចែកជា ២ រួមមាន ៖ **យុថ្កាហិរញ្ញវត្ថុសាធារណៈ និង វិធានប្រតិបត្តិ** ។

( សម្រាប់ព័ត៌មានលម្អិតបន្ថែមមាននៅក្នុងឯកសារដើមដែលមានភ្ជាប់មកជាមួយ )

## ២.៣. អាទិភាពគោលនយោបាយ

រាជរដ្ឋាភិបាលកម្ពុជា កំពុងផ្តោតសំខាន់លើការអនុវត្ត «យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១» ជាអាទិភាព ដើម្បីជំរុញកំណើនសេដ្ឋកិច្ច។ ជាមួយគ្នានេះ ក៏មានការដាក់ចេញកម្មវិធីសំខាន់ៗ ដូចជា ការលើកកម្ពស់ភាពប្រកួតប្រជែង ការពង្រីកវិស័យសេដ្ឋកិច្ច និងការពង្រឹងភាពធន់ និងការកែលម្អបរិយាកាសធុរកិច្ច និងវិនិយោគ (២០២៥–២០២៨) ។ គោលបំណងសំខាន់គឺដោះស្រាយបញ្ហាជារចនាសម្ព័ន្ធ ឱ្យមានប្រសិទ្ធភាព និងឆ្លើយតបទៅនឹងការផ្លាស់ប្តូរលឿន និងមិនប្រាកដប្រជា នៅក្នុងសេដ្ឋកិច្ចកម្ពុជា តំបន់ និងសកល កំពុងវិវត្តយ៉ាងឆាប់រហ័ស និងពិបាកប៉ាន់ស្មាន ។

**ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈ ២០២៧-២០២៩ នឹងចូលរួមគាំទ្រ អាទិភាពគោលនយោបាយសំខាន់ៗ ចំនួន ៧ រួមមាន ៖**

១. ការពារអធិបតេយ្យជាតិ និងបូរណភាពទឹកដី ព្រមទាំងធានាស្ថិរភាពនយោបាយ និងម៉ាក្រូសេដ្ឋកិច្ច

២. ខិតខំធានាលំនឹងជីវភាពប្រជាជន

៣. ធ្វើពិពិធកម្មសេដ្ឋកិច្ច និងអភិវឌ្ឍប្រភពកំណើនថ្មី

៤. ពង្រឹងបរិយាកាសធុរកិច្ច និងលើកស្ទួយវិស័យឯកជន រួមទាំងការបន្តបង្ក្រាបសកម្មភាពឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា

៥. អភិវឌ្ឍមូលធនមនុស្ស និងសង្គម

៦. បរិវត្តកម្មឌីជីថល និងអភិវឌ្ឍបៃតង

៧. ការពង្រឹងអភិបាលកិច្ច និងស្ថាប័ន

# គ. ក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ឆ្នាំ២០២៧-២០២៩

## គ.១. ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច

ស្ថានភាពម៉ាក្រូសេដ្ឋកិច្ច របស់កម្ពុជាត្រូវបានព្យាករថាមានភាពវិជ្ជមាន ប៉ុន្តែស្ថិតក្នុងបរិការណ៍ប្រុងប្រយ័ត្នខ្ពស់ ។ សេដ្ឋកិច្ចកម្ពុជាត្រូវបានព្យាករថានឹងបន្តនិន្នាការកើនឡើង ទោះបីជាមានសម្ពាធពីខាងក្រៅក៏ដោយ ។

**កំណើន ផ.ស.ស. ពិត ៖** ត្រូវបានព្យាករក្នុងរង្វង់ ៥,០% (កើន ០,៨ ពិន្ទុភាគរយ ធៀបនឹងឆ្នាំ ២០២៦ ដែលត្រូវប៉ាន់ស្មានកំណើន ៤,២%) នៅឆ្នាំ ២០២៧ នឹងរំពឹងថាងើបឡើងវិញក្នុងរង្វង់ ៥,៣% ទៅ ៥,៦% នៅឆ្នាំ២០២៨ - ២០២៩ ។

**អត្រាអតិផរណា ៖** ព្យាករថានឹងស្ថិតក្នុងកំណើនជាមធ្យមប្រហែល ២,៥% ក្នុងមួយឆ្នាំ សម្រាប់រយៈពេល ២០២៧-២០២៩ ។

**អត្រាប្តូរប្រាក់ ៖** អត្រាប្តូរប្រាក់រវាងរៀល និងដុល្លារអាម៉េរិក ត្រូវបានរក្សាឱ្យមានស្ថិរភាពយ៉ាងល្អប្រសើររក្សាក្នុងរង្វង់ ៤ ០៥០ រៀល ក្នុង ១ ដុល្លារអាម៉េរិក ។

**វិស័យនាំចេញ-នាំចូល ៖** បានបន្តរក្សានិន្នាការកើនឡើង ប៉ុន្តែការនាំចេញ តម្រូវឱ្យមានការពង្រឹង និងពង្រីកទៅលើវិស័យផ្សេងៗបន្ថែម ។

តារាង ៖ ក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចឆ្នាំ ២០២៣-២០២៩

| **សូចនាករ** | ២០២៣ | ២០២៤ | ២០២៥ | ២០២៦ប៉ាន់. | ២០២៧ព្យ. | ២០២៨ព្យ. | ២០២៩ព្យ. |
|---|---|---|---|---|---|---|---|
| **ផ.ស.ស. ថ្លៃបច្ចុប្បន្ន** (ប៊ីលានរៀល) | ១៧៤ ០២៧ | ១៨៨ ៧៦៦ | ២០៥ ៧៥៧ | ២១៩ ៩៣៩ | ២៣៥ ៨៨៣ | ២៥៣ ៥០១ | ២៧៣ ៣១២ |
| ផ.ស.ស. សម្រាប់ម្នាក់ (ដុល្លារអាម៉េរិក) | ២ ៤៧៧ | ២ ៦៧៥ | ២ ៩១៨ | ៣ ០៦៤ | ៣ ២៣៤ | ៣ ៤២៣ | ៣ ៦៣៨ |
| **កំណើន ផ.ស.ស. ពិត** (%) | ៥,០% | ៦,០% | ៥,៣% | ៤,២% | ៥,០% | ៥,៣% | ៥,៦% |
| អត្រាបរិត្តិផរណា ផ.ស.ស. (កំណើនប្រចាំឆ្នាំ) | ២,៣% | ២,៣% | ៣,៥% | ២,៥% | ២,៨% | ៣,៣% | ៣,១% |
| **អត្រាអតិផរណា** (**កំណើនជាមធ្យមប្រចាំឆ្នាំ**) | ២,១% | ០,៨% | ២,៦% | ៣,៨% | ២,៦% | ២,៥% | ២,៥% |
| អត្រាប្តូរប្រាក់ (រៀល/ដុល្លារអាម៉េរិក) | ៤ ១១០ | ៤ ០៧០ | ៤ ០១១ | ៤ ០២៩ | ៤ ០៤១ | ៤ ០៥០ | ៤ ០៥៨ |
| ការនាំចេញ (%នៃ ផ.ស.ស.) | ៥៥,៧% | ៥៧,៧% | ៦១,១% | ៦០,៧% | ៦១,៨% | ៦៣,៣% | ៦៤,៩% |
| ការនាំចូល (%នៃ ផ.ស.ស.) | -៦២,៧% | -៦៧,៤% | -៧២,០% | -៧២,១% | -៧៣,៥% | -៧៥,៣% | -៧៧,២% |
| សមតុល្យពាណិជ្ជកម្ម (%នៃ ផ.ស.ស.) | -៧,១% | -៩,៧% | -១០,៩% | -១១,៤% | -១១,៨% | -១២,០% | -១២,៣% |
| សមតុល្យគណនីចរន្ត (រួមបញ្ចូលបង្វែរ) (%នៃ ផ.ស.ស.) | ១,៣% | ០,៥% | -៣,៦% | -៧,៤% | -៧,៣% | -៦,៩% | -៦,៥% |
| ទុនបម្រុងអន្តរជាតិ (លានដុល្លារអាម៉េរិក) | ១៩ ៩៩៨ | ២២ ៥១១ | ២៧ ៥៣០ | ២៩ ១៦៩ | ៣០ ៨៦៧ | ៣៣ ១៥៩ | ៣៦ ២២១ |
| ចំនួនខែនៃការនាំចូល | ១០,១ | ៩,៦ | ៩,៨ | ៨,២ | ៨,០ | ៧,៩ | ៧,៨ |

ប្រភព ៖ វិទ្យាស្ថានជាតិស្ថិតិ និង ធនាគារជាតិនៃកម្ពុជា (២០២៣- ២០២៥), និងការព្យាកររបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (២០២៦-២០២៩)
( * ប៉ាន់. = ប៉ាន់ស្មាន, ព្យ. = ព្យាករណ៍ )

## គ.២. ក្របខ័ណ្ឌចំណូល-ចំណាយ រយៈពេលមធ្យម

ក្របខ័ណ្ឌចំណូល-ចំណាយ រយៈពេលមធ្យម ត្រូវបានព្យាករថានឹងមាននិន្នាការកើនឡើង ស្របតាមការអនុវត្តវិធានការគោលនយោបាយរបស់រាជរដ្ឋាភិបាលដែលដាក់ចេញក្នុង**«យុទ្ធសាស្ត្រកៀរគរចំណូលរបស់រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា»** ដែលជារបៀបវារៈកែទម្រង់របស់រាជរដ្ឋាភិបាល ក្នុងការធ្វើទំនើបកម្មប្រព័ន្ធសារពើពន្ធ និងប្រព័ន្ធចំណូលមិនមែនសារពើពន្ធ សំដៅធានា បាននូវការកៀរគរចំណូល ដោយមិនបង្កវិការភាពណាមួយដល់កំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍ ។



**ចំណូលសរុប** បែងចែកជាចំណូលចរន្ត និងចំណូលផ្សេងៗ ក្នុងនោះ ចំណូលចរន្តទទួលបានពីប្រភពធំៗចំនួន ២ គឺ ចំណូលសារពើពន្ធ (ពីអគ្គនាយកដ្ឋានពន្ធដារ, អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា) និង ចំណូលមិនមែនសារពើពន្ធ ។

**ចំណាយសរុប** ផ្តោតទៅលើចំណាយធំៗចំនួន ២ គឺ ចំណាយចរន្ត និងចំណាយមូលធន ។

តារាង ៖ ក្របខ័ណ្ឌចំណូល-ចំណាយរយៈពេលមធ្យម ឆ្នាំ ២០២៥-២០២៩

ឯកតា ៖ ប៊ីលានរៀល

| សូចនាករ | ២០២៥ប៉ាន់. | ២០២៦ច្ប. | ២០២៦កែ. | ២០២៧ព្យ. | ២០២៨ព្យ. | ២០២៩ព្យ. |
|---|---|---|---|---|---|---|
| **ចំណូលសរុប** | ៣៣ ៥២៣ | ៣២ ៧៤៧ | ៣៣ ៥៣៣ | ៣៥ ៩៥០ | ៣៨ ៤៣២ | ៤១ ៤៤៣ |
| **ចំណូលចរន្តសរុប** | ៣០ ៩៣៤ | ៣១ ៦១០ | ៣២ ៣៩៦ | ៣៤ ៨២៥ | ៣៧ ២៥៩ | ៤០ ១១៥ |
| អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា | ១២ ៦២៩ | ១២ ០៤៩ | ១២ ៣៥១ | ១៣ ៨៣៤ | ១៤ ៨៧៥ | ១៦ ០៧៨ |
| អគ្គនាយកដ្ឋានពន្ធដារ | ១៤ ៣៣៥ | ១៥ ២៨០ | ១៥ ៧៣១ | ១៦ ៤៧៨ | ១៧ ៥៣០ | ១៨ ៧៤៦ |
| ចំណូលមិនមែនសារពើពន្ធ | ៣ ៩៧០ | ៤ ២៨១ | ៤ ៣១៥ | ៤ ៥១៤ | ៤ ៨៥៤ | ៥ ២៩១ |
| **ចំណូលផ្សេងៗ** | ២ ៥៨៩ | ១ ១៣៧ | ១ ១៣៧ | ១ ១២៥ | ១ ១៧២ | ១ ៣២៨ |
| **ចំណាយសរុប** | ៣៦ ១៦៨ | ៤០ ៩១៣ | ៤០ ៩១៣ | ៤០ ១៧៥ | ៤២ ៣០១ | ៤៤ ៨៩៩ |
| ចំណាយចរន្តសរុប | ២៥ ៩២៧ | ២៧ ៣១៧ | ២៧ ៣១៧ | ២៩ ២៦៨ | ៣០ ៧៨៥ | ៣២ ៣៧៥ |
| ចំណាយមូលធនសរុប | ១០ ២៤១ | ១៣ ៥៩៦ | ១៣ ៥៩៦ | ១០ ៩០៧ | ១១ ៥១៧ | ១២ ៥២៤ |
| **អតិរេកចរន្ត** | ៥ ០០៨ | ៤ ២៩៣ | ៥ ០៧៩ | ៥ ៥៥៧ | ៦ ៤៧៤ | ៧ ៧៤០ |
| **ឱនភាពថវិកា** | -២ ៦៤៥ | -៨ ១៦៧ | -៧ ៣៨០ | -៤ ២២៥ | -៣ ៨៧០ | -៣ ៤៥៦ |

( * ប៉ាន់. = ប៉ាន់ស្មាន, ច្ប. = ច្បាប់ថវិកា, កែ. = ច្បាប់ថវិកាកែតម្រូវ, ព្យ. = ព្យាករណ៍ )

## គ.៣. ការគ្រោងវិភាជចំណាយសរុបថ្នាក់ជាតិ និងការវិភាជចំណាយថ្នាក់ជាតិតាមវិស័យ



ការគ្រោងវិភាជចំណាយសរុបថ្នាក់ជាតិ ៖

- **ក្នុងឆ្នាំ ២០២៧** ត្រូវបានគ្រោងក្នុងទំហំ ១៥,៨៩% នៃ ផ.ស.ស. ថមថយប្រមាណ -២,៥% ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២៦ ដែលបណ្តាលមកពីការធ្លាក់ចុះនៃធនធានហិរញ្ញប្បទានក្រៅប្រទេស ។
- **សម្រាប់ឆ្នាំ ២០២៨-២០២៩**, ចំណាយសរុបថ្នាក់ជាតិនឹងគ្រោងឱ្យមានកំណើនក្នុងអត្រាជាមធ្យមប្រមាណ ៥,៥% ក្នុងមួយឆ្នាំ ដែលនឹងស្ថិតក្នុងរង្វង់ ១៥,២៧% នៃ ផ.ស.ស. នៅឆ្នាំ ២០២៩ ។

តារាង ៖ ការគ្រោងវិភាជចំណាយសរុបថ្នាក់ជាតិតាមវិស័យ, កំណើនប្រចាំឆ្នាំនៃការវិភាជចំណាយថ្នាក់ជាតិតាមវិស័យ និងភាគរយនៃ ផ.ស.ស.

ឯកតា ៖ ប៊ីលានរៀល

| | ២០២៥ច្ប. | ២០២៦ច្ប. | ២០២៧ព្យ. | ២០២៨ព្យ. | ២០២៩ព្យ. |
|---|---|---|---|---|---|
| **ចំណាយសរុបថ្នាក់ជាតិ** | ៣៥ ៣៩៨ | ៣៨ ៤៥៣ | ៣៧ ៤៨៤ | ៣៩ ៣៩០ | ៤១ ៧៤៤ |
| %កំណើនប្រចាំឆ្នាំ | ០,០% | ៨,៦% | -២,៥% | ៥,១% | ៦,០% |
| %នៃ ផ.ស.ស. | ១៧,២០% | ១៧,៤៨% | ១៥,៨៩% | ១៥,៥៤% | ១៥,២៧% |
| **វិស័យរដ្ឋបាលទូទៅ** | ៣ ៤៥២ | ៣ ៤០៨ | ៣ ៧៤១ | ៤ ០៨៣ | ៤ ២៨៩ |
| %កំណើនប្រចាំឆ្នាំ | ០,៨% | -១,៣% | ៩,៨% | ៩,២% | ៥,០% |
| %នៃ ផ.ស.ស. | ១,៦៨% | ១,៥៥% | ១,៥៩% | ១,៦១% | ១,៥៧% |
| **វិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់** | ៥,៦៤១ | ៥,៧៤១ | ៦,៣៩៩ | ៦,៦៥០ | ៦,៨៩៧ |
| %កំណើនប្រចាំឆ្នាំ | -០,៣% | ១,៨% | ១១,៤% | ៣,៩% | ៣,៧% |
| %នៃ ផ.ស.ស. | ២,៧៤% | ២,៦១% | ២,៧១% | ២,៦២% | ២,៥២% |
| **វិស័យសង្គមកិច្ច** | ១០ ៦១៥ | ១០ ៩៨៩ | ១១ ៣៦៣ | ១២ ៣០៥ | ១២ ៩២០ |
| %កំណើនប្រចាំឆ្នាំ | ៦,០% | ៣,៥% | ៣,៤% | ៨,៣% | ៥,០% |
| %នៃ ផ.ស.ស. | ៥,១៦% | ៥,០០% | ៤,៨២% | ៤,៨៥% | ៤,៧៣% |
| **វិស័យសេដ្ឋកិច្ច** | ៨ ០១៧ | ៨ ២៣៤ | ៧ ៧៣៧ | ៨ ១៤០ | ៨ ៩៥៨ |
| %កំណើនប្រចាំឆ្នាំ | ០,៦% | ២,៧% | -៦,០% | ៥,២% | ៨,៨% |
| %នៃ ផ.ស.ស. | ៣,៩០% | ៣,៧៤% | ៣,២៨% | ៣,២១% | ៣,២៤% |
| **ចំណាយផ្សេងៗ** | ៧ ៦៧៣ | ១០ ០៨០ | ៨ ២៤៤ | ៨ ២១២ | ៨ ៧៨០ |
| %កំណើនប្រចាំឆ្នាំ | -៧,៨% | ៣១,៤% | -១៨,២% | -០,៤% | ៦,៩% |
| %នៃ ផ.ស.ស. | ៣,៧៣% | ៤,៥៨% | ៣,៥០% | ៣,២៤% | ៣,២១% |

( * ច្ប. = ច្បាប់ថវិកា, ព្យ. = ព្យាករណ៍ )

# គ.៤. ការគ្រោងចំណាយសរុបថ្នាក់ក្រោមជាតិ និងការព្យាករបំណុលសាធារណៈ ទៅនឹងសូចនាករវិធានហិរញ្ញវត្ថុសាធារណៈ

## កញ្ចប់ថវិកាថ្នាក់ក្រោមជាតិ សម្រាប់ឆ្នាំ២០២៧-២០២៩

ត្រូវបានគិតគូរអំពី ៖

ទី១. ការដំឡើងប្រាក់ឧបត្ថម្ភសម្រាប់ក្រុមប្រឹក្សា នៃរដ្ឋបាលថ្នាក់ក្រោមជាតិទាំង ៣ ថ្នាក់ និងមន្ត្រីភូមិព្រមទាំងសំដៅគាំទ្រដល់ការអភិវឌ្ឍ ។

ទី២. ការលើកកម្ពស់គុណភាពនៃសេវាសាធារណៈនៅមូលដ្ឋាន, ការផ្តល់ប្រាក់ឧបត្ថម្ភលំហែមាតុភាពដល់សមាជិកក្រុមប្រឹក្សាជាស្ត្រី សម្រាប់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិទាំង ៣ ថ្នាក់ និងការបន្តពង្រឹងសមត្ថភាពផ្នែករដ្ឋបាល, បច្ចេកទេស និងការគ្រប់គ្រងហិរញ្ញវត្ថុ ។

## ចំណាយសរុបថ្នាក់ក្រោមជាតិ

ចំពោះចំណាយសរុបរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងឆ្នាំ២០២៧ ត្រូវបានគ្រោងក្នុងទំហំ ១,៩០% នៃ ផ.ស.ស. ដែលរួមបញ្ចូលការឧបត្ថម្ភធនដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងទំហំ ០,៧៦% នៃ ផ.ស.ស. ។

សម្រាប់ឆ្នាំ២០២៨-២០២៩ ចំណាយសរុបរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានគ្រោងឱ្យមានកំណើនក្នុងអត្រាជាមធ្យមប្រមាណ៩,០% ក្នុងមួយឆ្នាំ ដែលនឹងស្ថិតក្នុងរង្វង់ ១,៩៥% នៃ ផ.ស.ស. នៅឆ្នាំ ២០២៩ ។

## ស្ថានភាពបំណុល

បំណុលសាធារណៈសរុបរបស់កម្ពុជា សម្រាប់ឆ្នាំ ២០២៧-២០២៩ ជាតម្លៃបច្ចុប្បន្ន ត្រូវបានប៉ាន់ស្មានថានឹងស្ថិតក្នុងកម្រិតជាមធ្យម ១៩,១៦% នៃ ផ.ស.ស. និងជាតម្លៃចារឹក ក្នុងកម្រិតជាមធ្យម ២៧,៤៥% នៃ ផ.ស.ស. ខណៈសូចនាករចំនួន ៤ ផ្សេងទៀតរបស់យុថ្កាហិរញ្ញវត្ថុសាធារណៈ ក៏ស្ថិតក្នុងកម្រិតទាបជាងពិតានដែលបានកំណត់ ។

តារាង ៖ ការព្យាករសូចនាករវិធានហិរញ្ញវត្ថុសាធារណៈ ឆ្នាំ ២០២៦-២០២៩

| សូចនាករ | អនុបាតគោល | ២០២៦ប៉ាន់. | ២០២៧ព្យ. | ២០២៨ព្យ. | ២០២៩ព្យ. |
|---|---|---|---|---|---|
| **១. យុថ្កាហិរញ្ញវត្ថុសាធារណៈ** | | | | | |
| អនុបាតតម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈសរុប ធៀបនឹង ផ.ស.ស. | ៥៥% | ១៩,២៥% | ១៩,២១% | ១៩,២១% | ១៩,០៤% |
| អនុបាតតម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈក្រៅប្រទេស ធៀបនឹង ផ.ស.ស. | ៤០% | ១៧,៨៩% | ១៧,៩១% | ១៧,៨៥% | ១៧,៩៤% |
| អនុបាតតម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈក្រៅប្រទេស ធៀបនឹង ការនាំចេញ | ១៨០% | ២៥,៦៦% | ២៥,១០% | ២៤,៣០% | ២៣,៧៣% |
| អនុបាតសេវាបំណុលសាធារណៈក្រៅប្រទេស ធៀបនឹង ការនាំចេញ | ១៥% | ១,៩៦% | ១,៨៩% | ១,៨៤% | ១,៧៧% |
| អនុបាតសេវាបំណុលសាធារណៈក្រៅប្រទេស ធៀបនឹង ចំណូលថវិកាជាតិ | ១៨% | ៨,៩៨% | ៨,៨៧% | ៨,៩២% | ៨,៨៣% |
| អនុបាតតម្លៃចារឹកនៃបំណុលសាធារណៈសរុប ធៀបនឹង ផ.ស.ស. | ៦៥% | ២៦,៩២% | ២៧,២៧% | ២៧,៥១% | ២៧,៥៧% |
| **២. វិធានប្រតិបត្តិ** | | | | | |
| ឱនភាពថវិកាសរុប | -៥% | -៣,៣៦% | -១,៧៩% | -១,៥៣% | -១,២៦% |

ប្រភព ៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

( * ប៉ាន់. = បាន់ស្មាន, ព្យ. = ព្យាករណ៍ )

# ៥. ហានិភ័យហិរញ្ញវត្ថុសាធារណៈ

ហានិភ័យហិរញ្ញវត្ថុសាធារណៈ សំដៅដល់ព្រឹត្តិការណ៍ ឬ ការប៉ះទង្គិចណាមួយ ដែលធ្វើឱ្យស្ថានភាពហិរញ្ញវត្ថុសាធារណៈប្រែប្រួល ដោយពុំបានគ្រោងទុក ដូចជា ការប្រមូលចំណូលសម្រេចបានទាបជាងការគ្រោងទុក និង/ឬ ទំហំនៃចំណាយសរុបច្រើនជាងការកំណត់ ដែលជាលទ្ធផលធ្វើឱ្យឱនភាពថវិការីកធំ ។ ក្នុងក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈ ២០២៧-២០២៩ នេះ, ហានិភ័យហិរញ្ញវត្ថុសាធារណៈត្រូវបានបែងចែកជា ៨ ហានិភ័យធំៗ ។



តារាង ៖ សេចក្តីសង្ខេបកម្រិតលទ្ធភាព និងទំហំកម្មវិបាកនៃហានិភ័យ

| កម្រិតលទ្ធភាព | ទំហំកម្មវិបាក | |
|---|---|---|
| ខ្ពស់ | ខ្ពស់ | ហានិភ័យម៉ាក្រូសេដ្ឋកិច្ច |
| ខ្ពស់ | ខ្ពស់ | ហានិភ័យពីវិស័យហិរញ្ញវត្ថុ |
| មធ្យម | មធ្យម | ភាពជឿទុកចិត្តបាននៃក្របខ័ណ្ឌ |
| មធ្យម | ទាប | ហានិភ័យបំណុលរបស់រដ្ឋាភិបាល |
| មធ្យម | ទាប | ហានិភ័យពីសហគ្រាសសាធារណៈ |
| មធ្យម | ទាប | ហានិភ័យពីវិនិយោគសាធារណៈ |
| មធ្យម | ទាប | ការប្រែប្រួលអាកាសធាតុ និងគ្រោះធម្មជាតិ |
| ទាប | ទាប | ភាពជាដៃគូរវាងរដ្ឋ និងឯកជន |

# ខ្លឹមសារសង្ខេប នៃហានិភ័យហិរញ្ញវត្ថុសាធារណៈ ដែលមានទំហំកម្រិតបាកខ្ពស់ និងលទ្ធភាពកើតឡើងខ្ពស់



**ហានិភ័យម៉ាក្រូសេដ្ឋកិច្ច ៖** សំដៅដល់ព្រឹត្តិការណ៍ ឬការវិវត្ត ណាមួយ ដែលបង្កជាផលអវិជ្ជមានដោយផ្ទាល់ និងប្រយោល ដល់ កំណើនសេដ្ឋកិច្ចជាតិដែលជាមូលដ្ឋានសម្រាប់ការរៀបចំក្របខ័ណ្ឌ ហិរញ្ញវត្ថុសាធារណៈ ។ ហានិភ័យម៉ាក្រូសេដ្ឋកិច្ចមានលទ្ធភាពកើត ឡើងក្នុងកម្រិតខ្ពស់ និងមានទំហំកម្មវិបាកក្នុងកម្រិតខ្ពស់ ដែលបង្ក ឡើងដោយកត្តាចម្បងចំនួន ៥ រួមមាន ៖

១. ភាពតានតឹងភូមិសាស្ត្រនយោបាយ និងសេដ្ឋកិច្ច ពិសេសសង្គ្រាមនៅតំបន់មជ្ឈិមបូព៌ា

២. ការផ្លាស់ប្តូរយ៉ាងឆាប់រហ័សនៃរបបពាណិជ្ជកម្មសកល

៣. ការថមថយសន្ទុះកំណើនសេដ្ឋកិច្ចសកល

៤. ភាពមិនច្បាស់លាស់នៃស្ថានភាពព្រំដែនកម្ពុជា-ថៃ

៥. ភាពមិនជោគជ័យនៃការកែទម្រង់ផ្ទៃក្នុង




**ហានិភ័យពីវិស័យហិរញ្ញវត្ថុ ៖** សំដៅដល់ការកើតមានវិបត្តិហិរញ្ញវត្ថុ នៃគ្រឹះស្ថានធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុ មិនមែនធនាគារដែលអាចបង្កើតជាកាតព្វកិច្ចបំណុលដោយផ្ទាល់ និងប្រយោល និងបង្កើនចំណាយ របស់រាជរដ្ឋាភិបាល ។ វិបត្តិក្នុងវិស័យហិរញ្ញវត្ថុ អាចបង្កើនបំណុល និងចំណាយរបស់រាជរដ្ឋាភិបាល ខណៈប៉ះពាល់ដល់ប្រាក់ចំណូលជាតិ ។ នៅពេល មានវិបត្តិ រដ្ឋត្រូវចំណាយបន្ថែមដើម្បីរក្សាស្ថិរភាពសេដ្ឋកិច្ច និងគាំទ្រស្ថាប័នហិរញ្ញវត្ថុដែលមានបញ្ហា ដែលអាចបង្កសម្ពាធលើ ហិរញ្ញវត្ថុសាធារណៈ ។ ការប្រែប្រួលក្នុងវិស័យនេះ ក៏ប៉ះពាល់ដល់សេដ្ឋកិច្ចជាទូទៅ និងជីវភាពប្រជាពលរដ្ឋ ហើយក៏ អាស្រ័យលើស្ថានភាពសេដ្ឋកិច្ច និងនយោបាយអន្តរជាតិផងដែរ ។

ទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ,
ផ្លូវលេខ ៩២, សង្កាត់វត្តភ្នំ, ខណ្ឌដូនពេញ,
រាជធានីភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា
www.pfm.gov.kh
gsc@pfm.gov.kh
(+៨៥៥) ៨៥ ៧៧៧ ៩២៤
www.facebook.com/gscpfm